ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ: ធ៧.០៩.០២០ ប្រ.ក

# ប្រកាស

## ស្តីពី

## ការតម្កល់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និង មាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារ ជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៩

## ស ម្រេ ច

### ប្រការ ១.-

ធនាគារពាណិជ្ជ ត្រូវតម្កល់ប្រាក់បំរុងកាតព្វកិច្ចនៃប្រាក់បញ្ញើនិងប្រាក់កម្ចីជាមធ្យមប្រចាំថ្ងៃ នៅធនាគារជាតិនៃកម្ពុជា ស្មើនឹងប្រាំបីភាគរយ(៨%)ចំពោះប្រាក់រៀល និងដប់ពីរភាគរយ(១២%)ចំពោះប្រាក់រូបិយប័ណ្ណ។

### ប្រការ ២.-

ធនាគារជាតិនៃកម្ពុជានឹងផ្តល់កំរៃការប្រាក់ ដូចខាងក្រោម:

- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រៀលចំនួនប្រាំបីភាគរយ(៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%)
- ចំពោះប្រាក់បំរុងកាតព្វកិច្ចជាប្រាក់រូបិយប័ណ្ណចំនួនដប់ពីរភាគរយ(១២%) ក្នុងនោះ ប្រាំបីភាគរយ (៨%) មានអត្រាការប្រាក់សូន្យភាគរយ (0%) និងបួនភាគរយ (៤%) បន្ថែមទៀត ផ្តល់អត្រាការប្រាក់ តាមប្រកាសស្តីពី ការកំណត់អត្រាការប្រាក់លើប្រាក់បញ្ញើមានកាលកំណត់ ប្រាក់បញ្ញើទុនបំរុងកាតព្វកិច្ច និងប្រាក់តម្កល់ធានាលើដើមទុនជារូបិយប័ណ្ណដុល្លារអាមេរិក។

**ប្រការ ៣.-**

ប្រកាសលេខ ធ៧.០៨.០៦៣ ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០០៨ ស្តីពីការតម្កល់ប្រាក់បម្រុងកាតព្វកិច្ច លើប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០៩

**ទេសាភិបាល**

**ជា-ចាន់តូ**

**<u>កន្លែងទទួល</u>**

- ដូចប្រការ ៤ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**<u>ចម្លងជូន</u>**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"